# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមរដ្ឋប្បវេណី**

-លេខ ៧៦ "ក"

ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២៤

-សំណុំរឿងរដ្ឋប្បវេណីលេខ ១៩៨៦

ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៣

បានបើកការទាញហេតុផលដោយផ្ទាល់មាត់ជាអសាធារណៈ នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤ នៅវេលាម៉ោង ៩ និង ០០នាទី ព្រឹក នៅសាលសវនាការទី៨ លើសំណុំរឿងរដ្ឋប្បវេណីលេខ១៩៨៦ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៣ ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

លោក[redacted]ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

លោក [redacted]ជាក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

**ដើមចោទនៃបណ្តឹងដើម និងជាចុងចម្លើយនៃបណ្តឹងតប តទៅនេះ ហៅថា "ដើមចោទ"**

-ឈ្មោះ [redacted] មុនីរ័ត្ន ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ មានអាសយដ្ឋាននៅ[redacted]។

**ចុងចម្លើយនៃបណ្តឹងដើម និងជាដើមចោទនៃបណ្តឹងតប តទៅនេះ ហៅថា "ចុងចម្លើយ"**

-ឈ្មោះ [redacted] ស្រីអូន ភេទស្រី អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ មានអាសយដ្ឋាន[redacted]។

**អ្នកតំណាងដោយអាណត្តិ**

-លោកស្រីមេធាវី [redacted]។

-លោកមេធាវី [redacted]។

### I.អង្គហេតុ និងចំណុចវិវាទ

**ក-ខ្លឹមសារសាលក្រមដែលទាមទារឲ្យតុលាការចេញ**

**ក-១.ដើមចោទនៃបណ្តឹងដើម និងជាចុងចម្លើយនៃបណ្តឹងតប**

១-សុំលែងលះពីចុងចម្លើយឈ្មោះ [redacted] ស្រីអូន។

២-សុំឱ្យចុងចម្លើយឈ្មោះ [redacted] **ស្រីអូន** ជាអ្នកមានអំណាចមេបាលើការគ្រប់គ្រង និងថែរក្សាកូនចំនួន ០២នាក់ ឈ្មោះ [redacted]មុនីរតនា ភេទស្រី កើតថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ និងឈ្មោះ[redacted]មុនីរតនៈ ភេទស្រី កើតថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ និងសុំបង់អាហារកាតព្វកិច្ចចិញ្ចឹមកូនទៅតាមលទ្ធភាព ហើយចុងចម្លើយត្រូវបង្កភាពងាយស្រួលឱ្យដើមចោទអាចចូលជួបប្រាស្រ័យទាក់ទងកូនៗ និងយកកូនៗទៅនៅជាមួយក្នុង ០១ខែៗចំនួន ០២ថ្ងៃ នៅថ្ងៃចុងសប្តាហ៍។

៣-សុំសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរួម៖ ម៉ូតូចំនួន ០២គ្រឿង (ម៉ាក HONDA DREAM១២៥ ស៊េរីឆ្នាំ២០១៦ ពាក់ផ្លាកលេខភ្នំពេញ ១FW-៨៥០៥ ចំនួន ០១គ្រឿង និងម៉ាក HONDA SUPER CUB ស៊េរីឆ្នាំ១៩៩៧ ពាក់ផ្លាកលេខ ១N-៨៩១១) និងសុំឱ្យចុងចម្លើយឈ្មោះ [redacted] **ស្រីអូន** ប្រគល់ប្រាក់ចំនួន USD ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក មកឱ្យដើមចោទ ជាថ្នូរដែលដើម



Scanned with CamScanner

ចោទឯកភាពប្រគល់ ដី និងផ្ទះលេខ៤ ផ្លូវបេតុង៦ (បុរីប៉ុនចេះ) សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និងគ្រឿងសង្ហារឹមក្នុងផ្ទះទាំងអស់ ឲ្យទៅចុងចម្លើយ។

៤-ដើមចោទជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

**ក-២.ចុងចម្លើយនៃបណ្តឹងដើម និងជាដើមចោទនៃបណ្តឹងតប**

១-សុំលែងលះពីដើមចោទឈ្មោះ [redacted] **មុនីរ័ត្ន**។

២-សុំសិទ្ធិជាអ្នកមានអំណាចមេបាលើការគ្រប់គ្រង និងថែរក្សាកូនចំនួន ០២នាក់ ឈ្មោះ [redacted] **មុនីរតនា** ភេទស្រី កើតថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ និងឈ្មោះ [redacted] **មុនីរតនៈ** ភេទស្រី កើតថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ និងសុំឲ្យដើមចោទបង់អាហារកាតព្វកិច្ចចិញ្ចឹមកូនទៅតាមលទ្ធភាព ឲ្យដើមចោទអាចចូលជួបប្រាស្រ័យទាក់ទងកូនៗ និងយកកូនៗទៅនៅជាមួយក្នុង ០១ខែៗចំនួន ០២ថ្ងៃ នៅថ្ងៃចុងសប្តាហ៍។

៣-សុំសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរួម ដី និងផ្ទះលេខ៤ ផ្លូវបេតុង៦ (បុរីប៉ុនចេះ) សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និងគ្រឿងសង្ហារឹមក្នុងផ្ទះទាំងអស់។

៤-សុំប្រគល់ទ្រព្យសម្បត្តិរួម៖ ម៉ូតូចំនួន ០២គ្រឿង (ម៉ាក HONDA DREAM១២៥ ស៊េរីឆ្នាំ២០១៦ ពាក់ផ្លាកលេខភ្នំពេញ ១FW-៨៥០៥ ចំនួន ០១គ្រឿង និងម៉ាក HONDA SUPER CUB ស៊េរីឆ្នាំ១៩៩៧ ពាក់ផ្លាកលេខ ១N-៨៩១១) និងប្រាក់ចំនួន USD ៣០,០០០ **(បីម៉ឺន) ដុល្លារអាមេរិក** ឲ្យទៅដើមចោទ ហើយដើមចោទឯកភាពប្រគល់ ដី និងផ្ទះលេខ៤ ផ្លូវបេតុង៦ (បុរីប៉ុនចេះ) សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និងគ្រឿងសង្ហារឹមក្នុងផ្ទះទាំងអស់ ឲ្យមកចុងចម្លើយ។

**ខ-ការសង្ខេបអំពីរឿងក្តី**

រឿងក្តីនេះ ជារឿងក្តីដែលដើមចោទនៃបណ្តឹងដើម និងជាចុងចម្លើយនៃបណ្តឹងតបឈ្មោះ [redacted] **មុនីរ័ត្ន** ប្តឹងទាមទារលែងលះពីចុងចម្លើយនៃបណ្តឹងដើម និងជាដើមចោទនៃបណ្តឹងតបឈ្មោះ [redacted] **ស្រីអូន**, សុំឲ្យចុងចម្លើយឈ្មោះ [redacted] **ស្រីអូន** ជាអ្នកមានអំណាចមេបាលើការគ្រប់គ្រង និងថែរក្សាកូនចំនួន ០២នាក់ ឈ្មោះ [redacted] **មុនីរតនា** ភេទស្រី កើតថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ និងឈ្មោះ [redacted] **មុនីរតនៈ** ភេទស្រី កើតថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ និងសុំបង់អាហារកាតព្វកិច្ចចិញ្ចឹមកូនទៅតាមលទ្ធភាព ហើយចុងចម្លើយត្រូវបង្កភាពងាយស្រួលឲ្យដើមចោទបានអាចចូលជួបប្រាស្រ័យទាក់ទងកូនៗ និងយកកូនៗទៅនៅជាមួយក្នុង ០១ខែៗចំនួន ០២ថ្ងៃ នៅថ្ងៃចុងសប្តាហ៍, សុំសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរួមមានម៉ូតូចំនួន ០២គ្រឿង (ម៉ាក HONDA DREAM ១២៥ ស៊េរីឆ្នាំ២០១៦ ពាក់ផ្លាកលេខភ្នំពេញ ១FW-៨៥០៥ ចំនួន ០១គ្រឿង និងម៉ាក HONDA SUPER CUB ស៊េរីឆ្នាំ១៩៩៧ ពាក់ផ្លាកលេខ ១N-៨៩១១) និងសុំឲ្យចុងចម្លើយឈ្មោះ [redacted] **ស្រីអូន** ប្រគល់ប្រាក់ចំនួន USD ៣០,០០០ **(បីម៉ឺន) ដុល្លារអាមេរិក** មកឲ្យដើមចោទ ជាថ្នូរដែលដើមចោទឯកភាពប្រគល់ ដី និងផ្ទះលេខ៤ ផ្លូវបេតុង៦ (បុរីប៉ុនចេះ) សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និងគ្រឿងសង្ហារឹមក្នុងផ្ទះទាំងអស់ឲ្យទៅចុងចម្លើយ ដោយផ្អែកលើសំបុត្រអាពាហ៍ពិពាហ៍លេខ០៨ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ជ្រោយចង្វារ និងផ្អែកលើការរស់នៅមិនចុះសម្រុងគ្នា បណ្តាលឲ្យអស់មនោសញ្ចេតនាមិនអាចរស់នៅជាមួយគ្នា។

និងជារឿងក្តីដែលចុងចម្លើយនៃបណ្តឹងដើម និងជាដើមចោទនៃបណ្តឹងតបឈ្មោះ [redacted] **ស្រីអូន** សុំលែងលះពីដើមចោទនៃបណ្តឹងដើម និងជាចុងចម្លើយនៃបណ្តឹងតបឈ្មោះ [redacted] **មុនីរ័ត្ន** , សុំសិទ្ធិជាអ្នកមានអំណាចមេបាលើការគ្រប់គ្រង និងថែរក្សាកូនចំនួន ០២នាក់ ឈ្មោះ [redacted] **មុនីរតនា** ភេទស្រី កើតថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ និងឈ្មោះ [redacted] **មុនីរតនៈ** ភេទស្រី កើតថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ និងសុំឲ្យដើមចោទបង់អាហារកាតព្វកិច្ចចិញ្ចឹមកូនទៅតាមលទ្ធភាព ឲ្យដើមចោទអាចចូលជួបប្រាស្រ័យទាក់ទងកូនៗ និងយកកូនៗទៅនៅជាមួយក្នុង ០១ខែៗចំនួន ០២ថ្ងៃ នៅថ្ងៃចុងសប្តាហ៍, សុំសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិរួម ដី និងផ្ទះ



Scanned with CamScanner

លេខ៤ ផ្លូវបេតុង៦ (បុរីប៊ុនចេះ) សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និងគ្រឿងសង្ហារឹមក្នុងផ្ទះទាំងអស់, សុំប្រគល់ទ្រព្យសម្បត្តិរួមមានម៉ូតូចំនួន ០២គ្រឿង (ម៉ាក HONDA DREAM១២៥ ស៊េរីឆ្នាំ២០១៦ ពាក់ផ្លាកលេខភ្នំពេញ ១FW-៨៥០៥ ចំនួន ០១គ្រឿង និងម៉ាក HONDA SUPER CUB ស៊េរីឆ្នាំ១៩៨៧ ពាក់ផ្លាកលេខ ១N-៨៩១១) និងប្រាក់ចំនួន USD ៣០,០០០ (បីម៉ឺន) **ដុល្លារអាមេរិក** ឱ្យទៅដើមចោទ ហើយដើមចោទឯកភាពប្រគល់ ដី និងផ្ទះលេខ៤ ផ្លូវបេតុង៦ (បុរីប៊ុនចេះ) សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និងគ្រឿងសង្ហារឹមក្នុងផ្ទះទាំងអស់ឱ្យមកចុងចម្លើយ ដោយផ្អែកលើសំបុត្រអាពាហ៍ពិពាហ៍លេខ០៨ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ជ្រោយចង្វារ និងផ្អែកលើការរស់នៅមិនចុះសម្រុងគ្នា បណ្តាលឱ្យរស់មនោសញ្ចេតនាមិនអាចរស់នៅជាមួយគ្នា។

## គ-ចំណុចគ្មានវិវាទ

-លែងលះ , សិទ្ធិអំណាចមេបាលើការគ្រប់គ្រង និងថែរក្សាកូន , ការបង់អាហារកាតព្វកិច្ចចិញ្ចឹមកូន , ប្រាស្រ័យទាក់ទងជាមួយកូន , បែងចែកទ្រព្យសម្បត្តិរួម និងប្រគល់ប្រាក់។

## ឃ-ចំណុចវិវាទ

-គ្មាន។

## ង-អង្គហេតុដែលអះអាងដោយគូភាគី

### ង-១.អង្គហេតុដែលអះអាងដោយដើមចោទនៃបណ្តឹងដើម និងជាចុងចម្លើយនៃបណ្តឹងតប

-ដើមចោទនៃបណ្តឹងដើម និងជាចុងចម្លើយនៃបណ្តឹងតបឈ្មោះ [redacted] មុនីរ័ត្ន បានធ្វើសេចក្តីថ្លែងការណ៍នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា៖ ខ្លួនសុំធ្វើការកែតម្រូវកម្មវត្ថុក្នុងពាក្យបណ្តឹង ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៣ ពីការទាមទារ ១.ឱ្យដើមចោទឈ្មោះ [redacted] មុនីរ័ត្ន លែងលះជាមួយចុងចម្លើយឈ្មោះ [redacted] ស្រីអូន។ ២.ឱ្យដើមចោទឈ្មោះ [redacted] មុនីរ័ត្ន ជាអ្នកមានអំណាចមេបាលើការគ្រប់គ្រង និងថែរក្សាកូនចំនួន ០២នាក់ ឈ្មោះ [redacted] មុនីរតនា ភេទស្រី កើតថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ និងឈ្មោះ [redacted] មុនីរតនះ ភេទស្រី កើតថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ និងសុំឱ្យចុងចម្លើយបង់អាហារកាតព្វកិច្ចចិញ្ចឹមកូនចំនួន ២,០០០,០០០ (ពីរលាន) រៀល។ ៣.សុំឱ្យតុលាការបែងចែកទ្រព្យសម្បត្តិរួមជា២ចំណែកស្មើគ្នា រួមមាន៖ ក.ដី និងផ្ទះលេខ៤ ផ្លូវបេតុង៦ (បុរីប៊ុនចេះ) សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និងគ្រឿងសង្ហារឹមក្នុងផ្ទះមានដូចជា សាឡុងមួយឈុត គ្រែគេងចំនួន០២ តុបាយ ១ឈុត និងទូទឹកកកចំនួន០១ សរុបចំនួន USD ៣,៩៥០ (បីពាន់ប្រាំបួនរយហាសិប) ដុល្លារអាមេរិក។ ខ.ប្រាក់បញ្ញើសន្សំក្នុងគណនីធនាគារ [redacted] ដែលមានគណនីលេខ [redacted] មានទឹកប្រាក់ចំនួន USD ៣៤,០០០ (បីម៉ឺនបួនពាន់) ដុល្លារអាមេរិក។ ៤.ឱ្យចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី។ **មកសុំទាមទារឱ្យតុលាការចេញសាលក្រមដូចតទៅ** ១-សុំលែងលះពីចុងចម្លើយឈ្មោះ [redacted] ស្រីអូន។ ២-សុំឱ្យចុងចម្លើយឈ្មោះ [redacted] ស្រីអូន ជាអ្នកមានអំណាចមេបាលើការគ្រប់គ្រង និងថែរក្សាកូនចំនួន ០២នាក់ ឈ្មោះ [redacted] មុនីរតនា ភេទស្រី កើតថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ និងឈ្មោះ [redacted] មុនីរតនះ ភេទស្រី កើតថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ និងសុំបង់អាហារកាតព្វកិច្ចចិញ្ចឹមកូនទៅតាមលទ្ធភាព ហើយចុងចម្លើយត្រូវបង្កភាពងាយស្រួលឱ្យដើមចោទអាចចូលជួបប្រាស្រ័យទាក់ទងកូនៗ និងយកកូនៗទៅនៅជាមួយក្នុង ០១ខែ១ចំនួន ០២ថ្ងៃ នៅថ្ងៃចុងសប្តាហ៍។ ៣-សុំសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិមានម៉ូតូចំនួន ០២គ្រឿង (ម៉ាក HONDA DREAM១២៥ ស៊េរីឆ្នាំ២០១៦ ពាក់ផ្លាកលេខ ភ្នំពេញ ១FW-៨៥០៥ ចំនួន ០១គ្រឿង និងម៉ាក HONDA SUPER CUB ស៊េរីឆ្នាំ១៩៨៧ ពាក់ផ្លាកលេខ ១N-៨៩១១) និងសុំឱ្យចុងចម្លើយឈ្មោះ [redacted] ស្រីអូន ប្រគល់ប្រាក់ចំនួន USD ៣០,០០០ **(បីម៉ឺន) ដុល្លារអាមេរិក** មកឱ្យដើមចោទ ជាថ្នូរដែលដើមចោទឯកភាពប្រគល់ ដី និងផ្ទះលេខ៤ ផ្លូវបេតុង៦ (បុរីប៊ុនចេះ) សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និងគ្រឿងសង្ហារឹមក្នុងផ្ទះទាំងអស់ឱ្យទៅចុង



Scanned with CamScanner

ចម្លើយ។ ៤-ដើមចោទជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី។ ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយឈ្មោះ [redacted] ស្រីអូន តាមប្រពៃណី កាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៦ តែបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅឆ្នាំ២០១៨ ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខ០៨ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩។ ក្នុងអំឡុងពេលរស់នៅជាមួយគ្នា ពួកខ្លួនតែងតែមានភាពរកាំរកូសមិនចុះសម្រុងនឹងគ្នា ដោយចេះតែរករឿងជាញឹកញាប់ និងចោទថាឲ្យប្រាក់ខែមិនទៀងទាត់ បណ្តាលឲ្យអស់មនោសញ្ចេតនាមិនអាចរស់នៅជាមួយគ្នា ហើយពួកខ្លួនរស់នៅបែកគ្នាចាប់តាំងពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣ រហូតដល់បច្ចុប្បន្ន។ បន្ទាប់ពីពួកខ្លួនរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាមានកូន ០២នាក់ ឈ្មោះ [redacted] **មុនីរតនា** ភេទស្រី កើតថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ និងឈ្មោះ [redacted] **មុនីរតនៈ** ភេទស្រី កើតថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ខ្លួនសុំប្រគល់ឲ្យចុងចម្លើយជាអ្នកមានសិទ្ធិអំណាចមេបា។ ចំពោះសោហ៊ុយចាំបាច់ដើម្បីថែរក្សាកូន ខ្លួនសុំបង់តាមលទ្ធភាព និងសុំចុងចម្លើយបង្កភាពងាយស្រួលឲ្យខ្លួនចូលជួបប្រាស្រ័យទាក់ទងជាមួយកូន និងអនុញ្ញាតឲ្យខ្លួនយកកូនៗទៅដើរលេង និងនៅជាមួយខ្លួនរយៈពេល ០២ថ្ងៃនៅថ្ងៃចុងសប្តាហ៍។ ក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ពួកខ្លួនមានទ្រព្យសម្បត្តិរួម ដី និងផ្ទះលេខ៤ ផ្លូវបេតុង៦ (បុរីប៊ុនចេះ) សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ , ម៉ូតូចំនួន ០២គ្រឿង (ម៉ាក HONDA DREAM១២៥ ស៊េរីឆ្នាំ២០១៦ ពាក់ផ្លាកលេខ ភ្នំពេញ 1FW-៨៥០៥ ចំនួន ០១គ្រឿង និងម៉ាក HONDA SUPER CUB ស៊េរីឆ្នាំ១៩៨៧ ពាក់ផ្លាកលេខ 1N-៨៩១១)។ ខ្លួនសុំគ្រប់គ្រងទ្រព្យសម្បត្តិរួមដែលមានម៉ូតូចំនួន ០២គ្រឿង (ម៉ាក HONDA DREAM១២៥ ស៊េរីឆ្នាំ២០១៦ ពាក់ផ្លាកលេខ ភ្នំពេញ 1FW-៨៥០៥ ចំនួន ០១គ្រឿង និងម៉ាក HONDA SUPER CUB ស៊េរីឆ្នាំ១៩៨៧ ពាក់ផ្លាកលេខ 1N-៨៩១១) និងសុំទាមទារឲ្យចុងចម្លើយឈ្មោះ [redacted] ស្រីអូន ប្រគល់ប្រាក់ចំនួន USD ៣០,០០០ (បីម៉ឺន) **ដុល្លារអាមេរិក** មកឲ្យខ្លួនជាថ្នូរដែលខ្លួនយល់ព្រមប្រគល់ទ្រព្យសម្បត្តិរួម ដី និងផ្ទះលេខ៤ ផ្លូវបេតុង៦ (បុរីប៊ុនចេះ) សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ (គ្រឿងសង្ហារឹមក្នុងផ្ទះទាំងអស់) ឲ្យទៅចុងចម្លើយ។

**ខ-២.អង្គហេតុដែលអះអាងដោយចុងចម្លើយនៃបណ្តឹងដើម និងជាដើមចោទនៃបណ្តឹងតប**

-ចុងចម្លើយនៃបណ្តឹងដើម និងជាដើមចោទនៃបណ្តឹងតបឈ្មោះ [redacted] ស្រីអូន បានធ្វើសេចក្តីថ្លែងការណ៍នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា៖ ខ្លួនសុំកែតម្រូវកម្មវត្ថុក្នុងពាក្យបណ្តឹងតប ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ពីសុំឲ្យតុលាការចេញសាលក្រម ១-ច្រានចោលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ [redacted] មុន្នីរ័ត្ន ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៣ ជាអសាបង់ចាប់ពីពេលនេះតទៅ។ ២-ចេញសាលក្រមលែងលះរវាងនាងខ្ញុំ និងដើមបណ្តឹងឈ្មោះ [redacted] មុន្នីរ័ត្ន។ ៣-ឲ្យនាងខ្ញុំជាអ្នកមានសិទ្ធិអំណាចមេបាលើការគ្រប់គ្រង និងថែរក្សាកូនស្រីទាំងពីរ ដែលកូនស្រីទី១ ឈ្មោះ [redacted] **មុនីរតនា** ភេទស្រី កើតថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ ទី២ឈ្មោះ [redacted] **មុនីរតនៈ** ភេទស្រី កើតនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ និងបង្គាប់អោយចុងចម្លើយនៃបណ្តឹងតបបង់អាហារកិច្ចដល់កូន១ចំនួន ២,០០០,០០០ (ពីរលាន) រៀលក្នុង០១ខែ រហូតដល់កូនពេញវ័យនីតិភាព។ ៤-ច្រានចោលការទាមទារប្រាក់បញ្ញើសន្សំក្នុងគណនីធនាគារ [redacted] ដែលមានគណនីលេខ [redacted] របស់ឈ្មោះ [redacted] មុន្នីរ័ត្ន។ ៥-កំណត់អចលនវត្ថុ (ដី និងផ្ទះ) ដែលមានទីតាំងស្ថិតនៅភូមិព្រែកលាភ សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ជាទ្រព្យដោយឡែករបស់នាងខ្ញុំ។ ៦-បែងចែកទ្រព្យរួមមានដូចជា៖ ម៉ូតូហុងដាឌ្រីម ០១គ្រឿងពណ៌ខៀវ-ខ្មៅ ស៊េរីឆ្នាំ២០១៦ និងគ្រឿងសង្ហារឹម ក្នុងផ្ទះមានតម្លៃសរុបប្រហែល ៣,៩៥០(បីពាន់ប្រាំបួនរយហាសិប) ដុល្លារអាមេរិក ជាពីរចំណែកស្មើគ្នា។ ៧-ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ចុងចម្លើយនៃបណ្តឹងតប។ **មកទាមទារ**ឲ្យតុលាការចេញសាលក្រម ១-សុំលែងលះពីដើមចោទឈ្មោះ [redacted] មុនីរ័ត្ន។ ២-សុំសិទ្ធិជាអ្នកមានអំណាចមេបាលើការគ្រប់គ្រង និងថែរក្សាកូនចំនួន ០២នាក់ ឈ្មោះ [redacted] **មុនីរតនា** ភេទស្រី កើតថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ និងឈ្មោះ [redacted] **មុនីរតនៈ** ភេទស្រី កើតថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ និងសុំឲ្យដើមចោទបង់អាហារកាតព្វកិច្ចចិញ្ចឹមកូនទៅតាមលទ្ធភាព ឲ្យដើមចោទអាចចូលជួបប្រាស្រ័យទាក់ទងកូនៗ និងយកកូនៗទៅនៅជាមួយក្នុង ០១ខែ១ចំនួន ០២ថ្ងៃ នៅថ្ងៃចុងសប្តាហ៍។ ៣-សុំសិទ្ធិគ្រប់គ្រងទ្រព្យ



Scanned with CamScanner

សម្បត្តិរួម ដី និងផ្ទះលេខ៤ ផ្លូវបេតុង៦ (បុរីប៊ុនថេះ) សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និងគ្រឿងសង្ហារឹមក្នុងផ្ទះទាំងអស់។ ៤-សុំប្រគល់ទ្រព្យសម្បត្តិមានម៉ូតូចំនួន ០២គ្រឿង (ម៉ាក HONDA DREAM១២៥ ស៊េរីឆ្នាំ២០១៦ ពាក់ផ្លាកលេខភ្នំពេញ ១FW-៨៥០៥ ចំនួន ០១គ្រឿង និងម៉ាក HONDA SUPER CUB ស៊េរីឆ្នាំ១៩៩៧ ពាក់ផ្លាកលេខ ១N-៨៩១១) និងប្រាក់ចំនួន USD ៣០,០០០ (**បីម៉ឺន**) **ដុល្លារអាមេរិក** ឱ្យទៅដើមចោទ ហើយដើមចោទឯកភាពប្រគល់ ដី និងផ្ទះលេខ៤ ផ្លូវបេតុង៦ (បុរីប៊ុនថេះ) សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និងគ្រឿងសង្ហារឹមក្នុងផ្ទះទាំងអស់ ឱ្យមកចុងចម្លើយ។ ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយដើមចោទឈ្មោះ [redacted] **មុនីរ័ត្ន** តាមប្រពៃណី កាលពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៦ តែបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅឆ្នាំ២០១៩ ដែលមានសំបុត្រអាពាហ៍ពិពាហ៍លេខ០៨ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩។ ក្នុងអំឡុងពេលរស់នៅជាមួយគ្នា ពួកខ្លួនតែងតែមានភាពរកាំរកូសមិនចុះសម្រុងនឹងគ្នា ដោយសារដើមចោទតែងតែដើរផឹកស៊ីផាត់យប់ ប្រើពាក្យសម្តីមិនសមរម្យ និងលាក់បាំងរឿងផ្សេងៗ បណ្តាលឱ្យអស់មនោសញ្ចេតនាមិនអាចរស់នៅជាមួយគ្នា ហើយពួកខ្លួនរស់នៅបែកគ្នាចាប់តាំងពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣ រហូតដល់បច្ចុប្បន្ន។ បន្ទាប់ពីពួកខ្លួនរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាមានកូន ០២នាក់ ឈ្មោះ [redacted] មុនីរតនា ភេទស្រី កើតថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ និងឈ្មោះ [redacted] **មុនីរតនៈ** ភេទស្រី កើតថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ខ្លួនសុំសិទ្ធិជាអ្នកមានអំណាចមេបាលើកូនទាំងពីរនាក់ ចំពោះសោហ៊ុយចាំបាច់ដើម្បីថែរក្សាកូន សុំឱ្យដើមចោទបង់តាមលទ្ធភាព ខ្លួនឯកភាពឱ្យដើមចោទអាចចូលជួបប្រាស្រ័យទាក់ទងកូនៗ និងយកកូនៗទៅនៅជាមួយក្នុង ០១ខែៗចំនួន ០២ថ្ងៃ នៅថ្ងៃចុងសប្តាហ៍។ ក្នុងអំឡុងពេលរៀបអាពាហ៍ពិពាហ៍ពួកខ្លួនមានទ្រព្យសម្បត្តិរួម ដី និងផ្ទះលេខ៤ ផ្លូវបេតុង៦ (បុរីប៊ុនថេះ) សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ , ម៉ូតូចំនួន ០២គ្រឿង (ម៉ាក HONDA DREAM១២៥ ស៊េរីឆ្នាំ២០១៦ ពាក់ផ្លាកលេខ ភ្នំពេញ ១FW-៨៥០៥ ចំនួន ០១គ្រឿង និងម៉ាក HONDA SUPER CUB ស៊េរីឆ្នាំ១៩៩៧ ពាក់ផ្លាកលេខ ១N-៨៩១១)។ ខ្លួនសុំគ្រប់គ្រងទ្រព្យសម្បត្តិរួម ដី និងផ្ទះលេខ៤ ផ្លូវបេតុង៦(បុរីប៊ុនថេះ) សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និងគ្រឿងសង្ហារឹមក្នុងផ្ទះទាំងអស់។ ប្រគល់ទ្រព្យសម្បត្តិរួមមានម៉ូតូចំនួន ០២គ្រឿង (ម៉ាក HONDA DREAM១២៥ ស៊េរីឆ្នាំ២០១៦ ពាក់ផ្លាកលេខ ភ្នំពេញ ១FW-៨៥០៥ ចំនួន ០១គ្រឿង និងម៉ាក HONDA SUPER CUB ស៊េរីឆ្នាំ១៩៩៧ ពាក់ផ្លាកលេខ ១N-៨៩១១) និងប្រាក់ចំនួន USD ៣០,០០០ (**បីម៉ឺន**) **ដុល្លារអាមេរិក** ទៅឱ្យដើមចោទ។

-លោកស្រីមេធាវី [redacted] និងលោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ថា: សូមឯកភាពចំពោះសេចក្តីថ្លែងការណ៍របស់កូនក្តី សូមឱ្យតុលាការសម្រេចតាមការស្នើសុំរបស់កូនក្តីខ្លួន។

## II.ការពិនិត្យភស្តុតាង

### ១.ភស្តុតាងជាឯកសាររបស់ដើមចោទ

១.១-ឯកសារ $X_{១}$៖ សំបុត្រអាពាហ៍ពិពាហ៍លេខ០៨ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ជ្រោយចង្វារ។

១.២-ឯកសារ $X_{២}$៖ សេចក្តីចម្លងសំបុត្រកំណើតលេខ៩៤ ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១៧ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ជ្រោយចង្វារ។

១.៣-ឯកសារ $X_{៣}$៖ សេចក្តីចម្លងសំបុត្រកំណើតលេខ១៥៦ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានសង្កាត់ជ្រោយចង្វារ។

១.៤-ឯកសារ $X_{៤}$៖ វិញ្ញាបនបត្រប្រាក់បញ្ញើ ធនាគារ អេស៊ីលីដា ភីអិលស៊ី ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០។

១.៥-ឯកសារ $X_{៥}$៖ កិច្ចសន្យាជួលផ្ទះ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩។



Scanned with CamScanner

ហើយគ្មានសង្ឃឹមថានឹងអាចធ្វើបដិវាទឡើងវិញបាន ដែលនេះបង្ហាញឱ្យឃើញថាការទាមទារលែងលះរបស់ដើមចោទ និងចុងចម្លើយ គឺស្របតាមមាត្រា ៩៧៨-ឃ-ង នៃក្រមរដ្ឋប្បវេណី ដែលគប្បីតុលាការសម្រេចឱ្យដើមចោទ និងចុងចម្លើយលែងលះគ្នា។

**២-ស្តីពីការទាមទារសិទ្ធិអំណាចមេបាលើកូន**

២-១.តាមភស្តុតាងឯកសារ $X_2$, $X_3$, $Y_2$, $Y_3$ និងតាមការអះអាងរបស់ដើមចោទ និងចុងចម្លើយ ដែលបានអះអាងថា ក្នុងការរស់នៅជាមួយគ្នាជាប្តីប្រពន្ធ ពួកគេមានកូនចំនួន ០២នាក់ឈ្មោះ [redacted] មុនីរតនា ភេទស្រី កើតថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ និងឈ្មោះ [redacted] មុនីរតនៈ ភេទស្រី កើតថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ធ្វើឱ្យតុលាការទទួលស្គាល់ថា ក្នុងការរស់នៅជាមួយគ្នាជាប្តីប្រពន្ធ ដើមចោទ និងចុងចម្លើយពិតជាមានកូនចំនួន ០២នាក់ឈ្មោះ [redacted] មុនីរតនា ភេទស្រី កើតថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ និងឈ្មោះ [redacted] មុនីរតនៈ ភេទស្រី កើតថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ពិតប្រាកដមែន។

២-២.ដើមចោទសុំប្រគល់សិទ្ធិជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] មុនីរតនា ភេទស្រី កើតថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ និងឈ្មោះ [redacted] មុនីរតនៈ ភេទស្រី កើតថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ឱ្យទៅចុងចម្លើយ ចំណុចនេះចុងចម្លើយក៏បានឯកភាព។ យោងតាមមាត្រា ១០៣៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី គប្បីតុលាការសម្រេចតាមការទាមទាររបស់ដើមចោទ។

**៣-ស្តីពីការទាមទារសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន**

-ដើមចោទ និងចុងចម្លើយបានឯកភាពគ្នាកំណត់ឱ្យដើមចោទ ក្នុងការបង់សោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនទាំង ០២នាក់តាមលទ្ធភាព ក្នុង០១ខែ ឱ្យទៅចុងចម្លើយឈ្មោះ [redacted] ស្រីអូន ហើយចំណុចនេះចុងចម្លើយក៏បានឯកភាព ហេតុនេះដើម្បីជាឧត្តមប្រយោជន៍កូនទាំង ០២នាក់ គប្បីតុលាការសម្រេចតាមការទាមទាររបស់ដើមចោទ។

**៤-ស្តីពីការទាមទារការសុំចូលជួប និងប្រាស្រ័យទាក់ទងកូន**

-ដើមចោទស្នើសុំចូលជួបប្រាស្រ័យទាក់ទងជាមួយកូនៗឈ្មោះ [redacted] មុនីរតនា ភេទស្រី កើតថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ និងឈ្មោះ [redacted] មុនីរតនៈ ភេទស្រី កើតថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ និងយកកូនៗទៅនៅជាមួយ ក្នុង ០១ខែៗចំនួន ០២ថ្ងៃ នៅថ្ងៃចុងសប្តាហ៍។ ការទាមទាររបស់ដើមចោទនេះ ចុងចម្លើយក៏បានឯកភាពផងដែរ។ ដូចនេះ ដើម្បីឱ្យកូនអាចមានឱកាសទទួលបានភាពកក់ក្តៅពីឪពុកខ្លះ និងដើម្បីទំនាក់ទំនងមនោសញ្ចេតនាឪពុក និងកូនឱ្យនៅស្ថិតស្ថេរនោះ យោងតាមមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី គប្បីតុលាការសម្រេចតាមការទាមទាររបស់ដើមចោទ។

**៥-ស្តីពីការទាមទារបែងចែកទ្រព្យសម្បត្តិរួម៖**

**៥-១.ការកំណត់អំពីទ្រព្យសម្បត្តិរួម**

ដើមចោទ និងចុងចម្លើយអះអាងដូចគ្នាថាទ្រព្យសម្បត្តិរួមរបស់ពួកគេមាន ដី និងផ្ទះលេខ៤ ផ្លូវបេតុង៦ (បុរីប៉ិនចេះ) សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ , ម៉ូតូចំនួន ០២គ្រឿង (ម៉ាក HONDA DREAM១២៥ ស៊េរីឆ្នាំ២០១៦ ពាក់ផ្លាកលេខ ភ្នំពេញ ១FW-៨៥០៥ ចំនួន ០១គ្រឿង និងម៉ាក HONDA SUPER CUB ស៊េរីឆ្នាំ១៩៩៧ ពាក់ផ្លាកលេខ ១N-៨៩១១) ដែលបានទិញក្រោយពេលរៀបអាពាហ៍ពិពាហ៍។ យោងតាមមាត្រា ៩៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ធ្វើឱ្យតុលាការទទួលស្គាល់ថាដី និងផ្ទះ និងម៉ូតូនេះគឺជាទ្រព្យសម្បត្តិរួមរបស់ដើមចោទ និងចុងចម្លើយ។

**៥-២.ការបែងចែកទ្រព្យសម្បត្តិរួម**

ដើមចោទ និងចុងចម្លើយសុំបែងចែកទ្រព្យសម្បត្តិរួម ដោយឱ្យតុលាការប្រគល់ទ្រព្យសម្បត្តិរួមមាន ម៉ូតូចំនួន ០២គ្រឿង (ម៉ាក HONDA DREAM១២៥ ស៊េរីឆ្នាំ២០១៦ ពាក់ផ្លាកលេខ ភ្នំពេញ ១FW-៨៥០៥ ចំនួន ០១គ្រឿង និងម៉ាក HONDA SUPER CUB ស៊េរីឆ្នាំ១៩៩៧ ពាក់ផ្លាកលេខ ១N-៨៩១១) ឱ្យមកដើមចោទ។ ប្រគល់ទ្រព្យសម្បត្តិរួម ដី និងផ្ទះលេខ៤ ផ្លូវបេតុង



Scanned with CamScanner

៦ (បុរីប៊ុនថេះ) សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ឱ្យទៅចុងចម្លើយ។ យោងតាមមាត្រា ៩៨០-១ នៃក្រមរដ្ឋប្បវេណី គប្បីតុលាការបែងចែកទ្រព្យសម្បត្តិរួមតាមការព្រមព្រៀងរបស់ដើមចោទ និងចុងចម្លើយ។

**៦-ស្តីពីការទាមទារសុំប្រគល់ប្រាក់ចំនួន USD ៣០,០០០ (បីម៉ឺនដុល្លារអាមេរិក) ឱ្យទៅដើមចោទឈ្មោះ [redacted] មុនីរ័ត្ន**

-ការទាមទាររបស់ដើមចោទដែលសុំឱ្យចុងចម្លើយឈ្មោះ [redacted] ស្រីអូន ប្រគល់ប្រាក់ចំនួន USD ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក ឱ្យទៅដើមចោទឈ្មោះ [redacted] មុនីរ័ត្ន ជាថ្នូរដែលដើមចោទបានឯកភាពប្រគល់ដី និងផ្ទះលេខ៤ ផ្លូវបេតុង៦ (បុរីប៊ុនថេះ) សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ (គ្រឿងសង្ហារឹមក្នុងផ្ទះទាំងអស់) ឱ្យទៅចុងចម្លើយ។ ការទាមទាររបស់ដើមចោទនេះ ចុងចម្លើយក៏បានឯកភាព និងបានប្រគល់ទទួលប្រាក់ តាមកំណត់ហេតុប្រគល់ទទួលប្រាក់ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤ រវាងគូភាគី និងមេធាវីតំណាងដោយអាណត្តិ រួចរាល់ហើយ។ គប្បីតុលាការសម្រេចតាមការទាមទាររបស់ដើមចោទនេះ។

**៧-បន្ទុកនៃប្រាក់ប្រដាប់ក្តី៖**

-នៅក្នុង "រឿងក្តីលែងលះនេះ" ដើមចោទអះអាងថា ខ្លួនជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី ដូច្នេះគប្បីឱ្យដើមចោទជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

## សេចក្តីសម្រេចបញ្ចប់

១-លែងលះដើមចោទឈ្មោះ [redacted] មុនីរ័ត្ន និងចុងចម្លើយឈ្មោះ [redacted] ស្រីអូន។

២-កំណត់ថាចុងចម្លើយឈ្មោះ [redacted] ស្រីអូន ជាអ្នកមានអំណាចមេបាលើឈ្មោះ [redacted] មុនីរតនា ភេទស្រី កើតថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ និងឈ្មោះ [redacted] មុនីរតនៈ ភេទស្រី កើតថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ដែលជាកូនរវាងដើមចោទ និងចុងចម្លើយ។

៣-ចុងចម្លើយឈ្មោះ [redacted] ស្រីអូន ត្រូវតែឱ្យឈ្មោះ [redacted] មុនីរតនា និងឈ្មោះ [redacted] មុនីរតនៈ ដែលជាកូនរវាងដើមចោទ និងចុងចម្លើយ ចូលជួបប្រាស្រ័យទាក់ទង និងឱ្យដើមចោទយកកូនទៅនៅជាមួយ ក្នុង ០១ខែ១ចំនួន ០២ថ្ងៃនៅថ្ងៃចុងសប្តាហ៍។ ចុងចម្លើយត្រូវបង្កភាពងាយស្រួលឱ្យដើមចោទអាចចូលជួបប្រាស្រ័យទាក់ទងកូន១ និងយកកូន១ទៅនៅជាមួយក្នុង ០១ខែ១ចំនួន ០២ថ្ងៃ នៅថ្ងៃចុងសប្តាហ៍។

៤-បង្គាប់ឱ្យដើមចោទឈ្មោះ [redacted] មុនីរ័ត្ន បង់សោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូនតាមលទ្ធភាព ក្នុង ០១ខែគិតត្រឹមថ្ងៃចុងក្រោយជារៀងរាល់ខែ ក្នុងអំឡុងពេលគិតចាប់ពីថ្ងៃដែលសាលក្រមនេះបានចូលជាស្ថាពរ រហូតដល់ឈ្មោះ [redacted] មុនីរតនា ភេទស្រី កើតថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៧ និងឈ្មោះ [redacted] មុនីរតនៈ ភេទស្រី កើតថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២០ ជាកូនរវាងដើមចោទ និងចុងចម្លើយ ក្លាយទៅជានីតិជន ឱ្យទៅចុងចម្លើយ។

៥-អំពីទ្រព្យសម្បត្តិរួម៖

ក-ប្រគល់ម៉ូតូចំនួន ០២គ្រឿង (ម៉ាក HONDA DREAM១២៥ ស៊េរីឆ្នាំ២០១៦ ពាក់ផ្លាកលេខ ភ្នំពេញ ១FW-៨៥០៥ ចំនួន ០១គ្រឿង និងម៉ាក HONDA SUPER CUB ស៊េរីឆ្នាំ១៩៩៧ ពាក់ផ្លាកលេខ ១N-៨៩១១) ឱ្យទៅដើមចោទឈ្មោះ [redacted] មុនីរ័ត្ន។

ខ-ប្រគល់ដី និងផ្ទះលេខ៤ ផ្លូវបេតុង៦ (បុរីប៊ុនថេះ) សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និងគ្រឿងសង្ហារឹមក្នុងផ្ទះទាំងអស់ ឱ្យទៅចុងចម្លើយឈ្មោះ [redacted] ស្រីអូន។

៦-បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ស្រីអូន ប្រគល់ប្រាក់ចំនួន USD ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក ឱ្យទៅដើមចោទឈ្មោះ [redacted] មុនីរ័ត្ន (ប្រាក់នេះបានប្រគល់ឱ្យដើមចោទឈ្មោះ [redacted] មុនីរ័ត្ន រួចរាល់ហើយ)។

៧-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីដើមចោទ។



Scanned with CamScanner

សាលក្រមនេះ បញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤ ចំពោះមុខដើមចោទឈ្មោះ [redacted] មុនីរ័ត្ន, ចំពោះមុខចុងចម្លើយឈ្មោះ [redacted] ស្រីអូន, ចំពោះមុខអ្នកតំណាងដោយអាណត្តិឲ្យចុងចម្លើយ និងប្រកាសជាអសាធារណៈ នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២៤។

គូភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

**ចៅក្រម**

**ហត្ថលេខា និងត្រា:** [redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃចន្ទ ១២កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែមករា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ចៅក្រម**

[redacted]



Scanned with CamScanner